# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៧១ អនក្រ.បក
### ស្តីពីការផ្ទេរឥណទាន

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និង ផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១**._ ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១៣០លានរៀល ( មួយរយសាមសិបលានរៀល) ពីជំពូក ៩១ ( ចំណាយឥតគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩ ។

www.pheakdeylaw.com

មាត្រា ២ ._ ឥណទានបើកក្នុងមាត្រា ១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់តបណ្តាញទូរស័ព្ទ អគ្គិសនី និង ទឹក ចូលទីតាំងអគារ ទីស្តីការក្រសួងវប្បធម៌ និង វិចិត្រសិល្បៈថ្មី ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី០៩ ខែ សីហា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យលេខ ៧២ អនក្រ.បក

## ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលបានប្រកាសឲ្យប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៩

### សំរេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

មាត្រា ១ ._ អនុក្រឹត្យនេះមានគោលបំណង ៖

-កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយ ក្រសួងបរិស្ថានមុន ដាក់ជូនរាជរដ្ឋាភិបាលសំរេច

-កំណត់ប្រភេទ និងទំហំគំរោង សកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

www.pheakdeylaw.com